# ការសំភាសន៍របស់អ៊ុំស្រី គី ពៅ

**កៈ អ្នកដែលសំភាសន៍ឈ្មោះ អ៊ុំ កន្និកា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ គី ពៅ**

**គៈ អ្នកចូលរួមក្នុងការសំភាសន៍គឺ កូនរបស់គាត់**

ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំស្រីដែលបានអនុញ្ញាតអោយនាងខ្ញុំធ្វើការសំភាសន៍អ៊ុំស្រីទាក់ទងទៅនិងជីវប្រវត្តិរបស់អ៊ុំស្រីផ្ទាល់ផងដែរហើយការសំភាសន៍មួយនេះគឺធ្វើឡើងដោយសាលាសកលវិទ្យាល័យ BYU ដោយសារតែសាលារបស់យើងមានគោលបំណងចង់ថែរក្សានូវជីវប្រវត្តិរបស់អ៊ុំទុកសំរាប់កូនចៅជំនាន់ក្រោយអោយគេបានដឹងលឺនិងទទួលបានបទពិសោធន៍ល្អៗពីខ្សែជីវិតរបស់អ៊ុំផងដែរហើយបន្ទាប់ពីការបញ្ចប់នូវការសំភាសន៍មួយនេះពួកយើងក៏សុំការអនុញ្ញាតពីអ៊ុំដើម្បីដាក់សំលេងរបស់អ៊ុំនិងចូលទៅក្នុងគេហទំព័ររបស់សាលាយើងដែលមានឈ្មោះថា wwwcambodianoralhistoriesbyuedu ផងដែរហើយខ្ញុំជាអ្នកសំភាសន៍គឺឈ្មោះ អ៊ុំ កន្និកាហើយកាលបរិច្ឆេតគឺនៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨ ហើយទីកន្លែងគឺនៅភូមិ វាល ឃុំ ច្រៀវ ស្រុក សៀមរាប ខេត្តសៀមរាបផងដែរ ហើយយើងនិងទៅជួបគាត់ទាំងអស់គ្នា!

កៈ ជំរាបសួរអ៊ុំស្រី!

ខៈ (សើច)!

កៈ តើអ៊ុំស្រីដូចថាមានឈ្មោះអ្វីដែរ?

ខៈ ឈ្មោះ ពៅ! (សើច)

កៈ ឈ្មោះ ពៅ តែម្តងអ្ហោះអ៊ុំស្រី?

ខៈ ឈ្មោះ គី ពៅ!

កៈ គី ពៅ? អញ្ចឹងត្រកូលរបស់អ៊ុំគឺ ពៅណោះអ៊ុំណោះ?

ខៈ ចាំ!

ក៖ ហើយឈ្មោះរបស់អ៊ុំ គឺ ពៅ?

ខ៖ ចា៎!

ក៖ ឈ្មោះ ពៅ ឈ្មោះពិរោះអ្វីណា៎អ៊ុំ?

ខ៖ អូយមិនដឹងជាពិរោះអី!

ក៖ (សើច) ចុះអ៊ុំមានឈ្មោះហៅក្រៅដែលថាអ្នកជិតខាងគេដាក់អោយគេធ្លាប់ហៅយាយអី យាយអីអញ្ចឹងអ្នាស?

ខ៖ អត់មានទេ!

ក៖ អ៎អត់មានទេ!

គ៖ គេហៅគាត់តែ យាយពៅ យាយពៅ!

ក៖ យាយ ពៅ! ឈ្មោះតែមួយនេះឯង?

ខ៖ ឈ្មោះក្នុងសៀវភៅគ្រួសារគឺតែមួយដូចគ្នា!

ក៖ ចា៎ចុះដូចពីនៅក្មេងអ៊ុំមានធ្លាប់ឪពុកម្ដាយដាក់រហ័សនាមថាកូនឈ្មោះអីអញ្ចឹងអ្នាស! ដូចញ៉ុមអញ្ចឹងកាលពីទូចដាក់រហ័សនាមថាក្រញ៉ាញ់អីអញ្ចឹងឬទៅដោយសារសក់របស់ខ្ញុំរួញៗអ្នាស! អញ្ចឹងតើអ៊ុំមានទេរហ័សនាមបែបនិងទេ?

ខ៖ អត់!

ក៖ អត់មានទេណោះអ៊ុំណោះ? ឈ្មោះតែមួយនេះឯង?

ខ៖ តែមួយនេះឯង!

ក៖ អ៎សម័យពីដើមយើងអត់សូវមានឈ្មោះហៅរញ៉េរញ៉ៃដូចសម័សខ្ញុំទេអ្នោះអ៊ុំ? ខុះដូចជាអាយុរបស់អ៊ុំវិញតើអ៊ុំមានអាយុប៉ុន្មានហើយអ៊ុំ?

ខ៖ សែសិបប្រាំបួន!

កៈ អ៊ុំមានអាយុ សែសិបប្រាំបួនឆ្នាំហើយតើអ៊ុំចាំទេថាអ៊ុំកើតនៅក្នុងឆ្នាំណាខែណាថ្ងៃណាផង ដែរ?

ខៈ ក៏ដែលចាំម៉ាក់តិចទេវង្វេងអស់ហើយ!

កៈ អូយអ៊ុំភ្លេចអស់ហើយឆ្នាំក៏អត់ចាំដែរណោះអ៊ុំ?

ខៈ ទាល់តែមើលសៀវភៅគ្រួសារបានដឹង!

កៈ អញ្ចឹងឆ្នាំខ្មែរអ៊ុំអាចចាំទេ?

ខៈ អ់! ឆ្នាំខ្មែរចាំខ្លះ!

កៈ ឆ្នាំខ្មែរដូចជា ជូត ឆ្លូវ ខាលីអ្នាស? កើតឆ្នាំណាដែរ?

ខៈ ចាំកើតដឹងតាខែឆ្នាំដែរកើតណាស់លោកគ្រូបើថ្ងៃអត់ដឹងទេ!

កៈ ចា៎អ៎ថ្ងៃអត់ថ្ងៃអត់ចាំទេចា៎អ៊ុំអាចប្រាប់តែខែខ្មែរនិងឆ្នាំខ្មែរក៏បានដែរ!

ខៈ កើតឆ្នាំ(សើច)ឆ្នាំចរ!

កៈ ឆ្នាំចរណោះអ៊ុំណោះ? ចុះខែវិញ?

ខៈ ខែភទ្របទ!

កៈ ខែ ភទ្របទអញ្ចឹងអ៊ុំចាំតែខែខ្មែរឆ្នាំខ្មែរទេ?

ខៈ ចា៎!

កៈ ចា៎ចុះទីកន្លែងកំណើតវិញតើអ៊ុំចាំទេថាអ៊ុំកើតនៅទីណាដែរ?

ខៈ កើតនៅទីនេះឯង!

កៈ ម្តុំនិងគេហៅអីគេដែរអ៊ុំ?

ខៈ ម្តុំនិងភូមិ វាល ឃុំ ច្រៀវ

កៈ ភូមិ វាល ឃុំ ច្រៀវ ស្រុក សៀមរាប ខេត្ត សៀមរាប?

ខៈ និងឯង!

កៈ អ៎ចាំអញ្ចឹងតើដូចជាសាច់សាលោហាតដែរថាតពីជីដូនជីតាម៉ោគឺនៅទីនេះម៉ោរហូតឬក៏បងទើបនិងផ្លាស់ប្ដូរម៉ោទេ?

ខៈ ពីពីអង្កាលខ្ញុំមិនទាន់កើតម៉ែខ្ញុំគាត់នៅបទជៀបទជៀយើងស្ពាននាគនិង

កៈ ចាំ!

ខៈ ដល់ពេលចូលស្រុកម៉ោបែកបាក់គ្នាជំនាន់អាពតម៉ោគឺមកនៅទីនេះ!

កៈ អញ្ចឹងអ៊ុំមកនៅតាំងពីឆ្នាំមួយពាន់ប្រាំបួនរយជិតសិបប្រាំបួនរ្អោះអ៊ុំ?

ខៈ ចាំនៅនិយាយរួមទៅនៅតាំងពីស្រុកកំណើតដូនតារហូតម៉ោ! តែកាលយើងជំនាន់អាពតម៉ោយើងចេះតែជំលៀសទៅណាំ!

កៈ ជំលៀសទៅឆ្ងាយតែម៉ោវិញ?

ខៈ និងហើយក៏យើងម៉ោវិញនៅកន្លែងយើងវិញម៉ោណាំស!

កៈ អ៎ចាំល្អមែបទែនអញ្ចឹងទីកន្លែងនេះអីរស់នៅសុខសប្បាយទេណោះអ៊ុំណោះ?

ខៈ ទេមានអីធម្មតា!

កៈ អញ្ចឹងទីនេះមានសុខសុវត្ថិភាពធម្មតាអត់មានមានសំបូរចោរអីអត់មានទេ?

ខៈ នៅឯណោះគ្មានចោរទេម៉ូតូដាក់តែក្រោមនេះរ្អោសប៉ិនមិនដែលមានចោរលក់ទេ! មិនដែរមានបន្ទប់បន្ទឹងឯណាដាក់បួនប្រាំៗម៉ូតូក៏ដាក់ចោលទៅ!

កៈ មិនមានចោរឯណាំទេម្ដុំនេះ! ដោយសារមានគេហៅថាអ្នកគ្រប់គ្រងភ្អមានសន្តិសុខសន្តិភាពអញ្ចឹងទៅអត់សូវមានចោរណាហ៊ានដើរចូលទេណោះអ៊ុំណោះ? ចុះដូចជាអ៊ុំស្រីវិញមានបងប្អូនបង្កើតប៉ុន្មានអ្នកដែរអ៊ុំ?

ខៈ នៅសល់នៅសល់ប៉ុន្មាននាក់អញ្ចេះមើស មួយពីរបីនាក់បួននាក់!

កៈ ប្អូននាក់អីណោះអ៊ុំ?

ខៈ ចា៎!

កៈ ចុះអ្នកឯទៀតនិងគាត់ទៅណាដែរ?

ខៈ ពួកគាត់ស្លាប់!

កៈ ស្លាប់អស់ប៉ុន្មានដែរអ៊ុំ?

ខៈ ស្លាប់អស់ប៉ុន្មានអញ្ចេះ? មើសស្លាប់ជំនាន់អាពតស្លាប់អស់ពីរពេលចូលស្រុកទើបនិង ស្លាប់មើសទើបប្អូនប្រាំឆ្នាំនេះអស់ពីរនាក់ទៀត!

កៈ អ៎ចា៎អញ្ចឹងគាត់ស្លាប់ដោយសារជំងឺអ្វោះ?

ខៈ ចា៎ស្លាប់ដោយសារជំងឺ!

កៈ អ៎!

ខៈ ជំងឺលើសឈាម!

កៈ គាត់លើសឈាមតែគាត់មានធ្វើទុក្ខអីខ្លះទេ?

ខៈ អត់ផងតែគាត់ដើរទៅដូចជំពប់ជើងទៅដួលទៅដូចថាជំពប់ជើងទៅក៏ទៅស្លឹបរហូត!

កៈ អញ្ចឹងគាត់ស្លាប់បណ្ដោយ!

ខៈ ចា៎ទៅពេទ្យដល់ពេទ្យក៏ងាប់!

កៈ ចុះមានអ្នកណាដែរស្លាប់ជំនាន់អាពតទេអ៊ុំ?

ខៈ បងខ្ញុំងាប់ពីរ

កៈ គេយកវ៉ៃចោលអ្វោះអ្ហ៎អ៊ុំក៏ជំងឺ?

ខៈ បាត់ខ្លួនមិនដឹងថាគាត់នៅទីណាក្មួយ!

កៈ អ៎ចាំបាត់ខ្លួននិងឈ្មោះអីខ្លះអ៊ុំ?

ខៈ ឈ្មោះឈ្មោះវាមានពីរឈ្មោះគឿនហើយទៅឈ្មោះអីមួយទៀតទេ

កៈ មិនដឹងឈ្មោះអីទេ!

ខៈ ម៉ែបានគាត់ចាំតែខ្ញុំអត់ចាំទេ!

កៈ អ៎ដឹងតែគាត់ថាបានបែកគ្នាពេលជំលៀសមកវិញអីណោះអ៊ុំណោះ?

ខៈ ចាំតែរូបថតក៏គ្មាន!

កៈ អ៎អញ្ចឹងអ៊ុំបាត់បងប្អូនមួយនាក់?

ខៈ និងហើយមួយទៀតឈឺ

កៈ អ៎ឈឺស្លាប់! ដោយសារសម័យអាពតនិងអត់សូវមានថ្នាំព្យាបាលបង្ការអីណោះអ៊ុំណោះ?

ខៈ អត់ទេ! ដូចថាយើងត្រូវដូចថាយើងវាកើតអាជំងឺទាចទឹកទៅណា៎ស

កៈ ចាំអ៎!

ខៈ គាត់ធំពោះ!

កៈ អញ្ចឹងមិនដឹងព្យាបាលយ៉ាងមិចដែរនិងអ្នាសអ៊ុំ!

ខៈ នោះឯងអញ្ចឹងទៅវាដូចកើតលឿងអញ្ចឹងឯង

កៈ អញ្ចឹងតើអ៊ុំជាកូនទីប៉ុន្មានដែរក្នុងគ្រួសារអ៊ុំ?

ខៈ ខ្ញុំកូនទីប៉ុន្មានដែរទេម៉ែខ្ញុំកូនច្រើនណាស់!

កៈ អ៊ុំអាចរាប់ត្រួសៗ!

ខៈ គាត់កូនឡើងដប់ពីរនាក់ណ៎

កៈ អូអញ្ចឹងអ្ហោះអ៊ុំ! កូនដប់ពីរនាក់!

ខ៖ ចាំប៉ុន្តែពួកគាត់ភាគច្រើនស្លាប់អ្នោះអ៊ុំ?

ខ៖ ចាំបងៗងាប់អស់ហើយ!

ក៖ អញ្ចឹងអ៊ុំអត់ដឹងថាអ៊ុំជាកូនទីប៉ុន្មានទេ?

ខ៖ ទេមើលនៅនៅបងប្រុសខ្ញុំមួយរួចនៅអាមួយទៀតនោះដែរធ្វើការនៅក្នុងខេត្តនោះមួយទៀតប្អូនស្រីនោះនៅផ្ទះថ្មធំនូកនោះឯងបងប្អូនបួននាក់!

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មានអ៊ុំ?

ខ៖ ប្រុសពីរស្រីពីរ!

ក៖ អូចាំក្រៅពីនិងដឹងថាបាត់ខ្លួនអស់ហើយ!

ខ៖ ទៅវិញបាត់អស់ហើយ!

ក៖ អញ្ចឹងតើអ៊ុំអាចនៅចាំឈ្មោះអ្នកដែលបានស្លាប់និងបាត់ខ្លួននិងទេ?

ខ៖ ដែលស្លាប់និងឈ្មោះ សាកន!

ក៖ សាកន?

ខ៖ នោះឯង!

ក៖ គាត់ដែលស្លាប់នៅជំនាន់អាពត?

ខ៖ ចាំ!

ក៖ ចុះអ្នកឯទៀតអ្នោះអ៊ុំ?

ខ៖ ឈ្មោះ ហឿន!

ក៖ ឈ្មោះ ហឿន!

ខ៖ ឈ្មោះ ប៉ោង

ក៖ ប៉ោង?

ខ៖ នោះឯង!

ក៖ សុទ្ធតែអ្នកស្លាប់ណោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ ចាំចុះអ្នកបាត់ខ្លួនម្លោះអ៊ុំគាត់មានឈ្មោះអីដែរ?

ខ៖ អ៊្វខ្ញុំមិនស្គាល់បងប្អូនម៉ែទេ!

ក៖ កូន!

ខ៖ អកអោះកូនម៉ែ!

ក៖ កូនអ៊ុំច្រើនៗកូនអ៊ុំស្រីម្ដាយអ៊ុំកូនគាត់ច្រើន!

ខ៖ កូនគាត់ច្រើនតែម្ដាយខ្ញុំព្រោះខ្ញុំធំដឹងក្ដីម៉ោគាត់ថាកូនគាត់ដប់ពីរប៉ុន្តែថាមិនបានរស់ទាំងអស់ទេ!

ក៖ ចាំ!

ខ៖ ធំតាដែលអោយម្ដាយឃើញមើសប៉ុន្មានអញ្ចេះមើលរាប់នៅអ៊ុំហ៊ឹងរាប់តាំងអាងាប់អាអុយម្លោះ?

ក៖ ចាំ!

ខ៖ រាប់តាំងអ៊ុំ ហ៊ឹងអ៊ុំហឿនអ៊ុំប៉ោងសាកន ណាកឿន អ៊ុំ ងិក

គ៖ អ៊ុំជឿ!

ខ៖ អ៊ុំជឿ ខ្ញុំ អ៊ុំ ប៉ោត នៅបងប្អូនប្រាំបួននាក់រស់!

ក៖ អញ្ជឹងអ៊ុំជាកូនទីប្រាំបីម្លោះអ៊ុំ?

ខ៖ មិនដឹងកូនទីប៉ុន្មានទេ?

កៈ ចាំ! តែអ៊ុំនៅតែចាំឈ្មោះពួកគាត់ណោះអ៊ុំណោះ?

ខៈ ចាំ!

កៈ អញ្ចឹងអ៊ុំកើតទាន់បងប្អូនណាហើយកើតមិនទាន់បងប្អូនណាឬក៏អ៊ុំនៅក្មេងពេកអីអញ្ចឹងអ្នាសណោះអ៊ុំ?

ខៈ ទាន់បងខ្ញុំដែរបាត់ខ្លួននិង! ពេលនិងខ្ញុំធំហើយខ្ញុំធំដឹងតាស្គាល់បងខ្ញុំ។

កៈ អ៊ុំធំដឹងក្តី! អ៊ុំនៅចាំមុខរបស់គាត់ទេ?

ខៈ ប៉ុន្តែជំនាន់នុងជំនាន់ លន់នល់គាត់ម៉ោម្តង!

កៈ គាត់ម៉ោរកអ៊ុំអ្ហោះគាត់ម៉ោរកជាលក្ខណៈ?

ខៈ ម៉ោ(យំ) គាត់ថាបើឃើញម៉ោរស់បើអត់ឃើញម៉ោគាត់ងាប់។

កៈ ផ្តាំអ៊ុំណោះអ៊ុំ ថាបើឃើញម៉ោរស់ហើយតែបើអត់ឃើញម៉ោគាត់ស្លាប់ហើយហើយឥលូវអ៊ុំអត់ឃើញគាត់ម៉ោមែន?

ខៈ អត់! អញ្ចឹងមានន័យថាគាត់

ខៈ អូគ្រួសារខ្ញុំពិបាកអ្នាស!

កៈ ចាំអ៊ុំឆ្លងកាត់ច្រើន!

ខៈ ម៉ែក៏ពិបាកឪខ្ញក៏ពិបាកជំនាន់អាពតបែកបាក់គ្នាខ្ញុំនៅរស់នៅជាមួយឪម៉ែគេចាប់ដាក់គុក!

កៈ គេចាប់ម៉ែដាក់គុកទៀត! អញ្ចឹងអ៊ុំស្រីគាត់ជាប់នៅគុកទួលស្លែងអ្ហោះ?

ខៈ នោះឯង!

កៈ អ៎អញ្ចឹង!

ខៈ កូនគាត់ក៏បែកបាក់ពេញវាល!

កៈ តើហេតុអីបានជាគេចាប់អ៊ុំស្រីដាក់ក្នុងគុកទួលស្លែងដែរអ៊ុំដឹងទេ?

ខ គេថាយើងនេះទុកលាក់ដូចថាយើងនិងចានឆ្នាំងអុយរបស់របរយើងប្រើប្រាស់អញ្ចេះក៏យើងមិនបានទៅយកទៅដាក់រួមដាក់សហាករណ៍ណាំៗយើងគាត់ដូចថាយើងមាន់អន្លង់យើលាក់តដៅន្លូងទៅអីចោលទៅដល់ពេលគេទៅគេឆែកគេអុយគេឃើញទៅគេក៏សាងយើង។

ក៖ ចាំ!

ខ៖ ពិបាករស់នៅណាស់!

ក៖ អុំអាណិតម្ដាយអុំអ្ហាសណេះអុំណេះ? អញ្ចឹងអុំគិតថាម្ដាយអុំស្លាប់នៅក្នុងគុកទួលស្លែងនិងឬក៏អត់?

ខ៖ អត់ទេមិនមែនទេម៉ែខ្ញុំមានមិត្តគេរំដោះម៉ោ

ក៖ អុំ!

ខ៖ រំដេម៉ោបានប្រហែលបីឆ្នាំ! គេយកឪខ្ញុំទៅម្ដងឪខ្ញុំគេស្មើរដាក់ឡានអាគ្រប់ផាងដូងទៅក៏ម៉ែរស់ក៏ងាប់ទ! ម៉ែជាប់គុកមិនងាប់ងាប់ឪ!

ក៖ ចាំចុះប៉ារបស់អុំគាត់ធ្វើអីដែរបានជាគេយកគាត់ទៅកសាង?

ខ៖ គាត់ធ្វើផ្ទះគំរូ!

ក៖ គាត់លួចសាងសង់ផ្ទះអ្ហោះ?

ខ៖ គាត់ធ្វើគេជួលគាត់គេដូចថាគេអោយយើងធ្វើផ្ទះគំរូទៅណាស់ដោយសារតែគាត់ជាងធ្វើតាមដូចថាអោយដូចៗគ្នាទៅរាប់រយខ្នង!

ក៖ អាពតអ្នកអោយអ្នកបញ្ជាអោយធ្វើអ្ហោះ!

ខ៖ ចាំគាត់ធ្វើអញ្ចេះឯង!

ក៖ ចុះគាត់អ្នកចេញមុខធ្វើ!

ខ៖ ចុះជាងគ្រប់តែគ្នានោះឯងអ្នកចេះជាង!

ក៖ ចាំ!

ខ៖ ធ្វើ! មានការងារអុយគេថាដូចថាអ្នកណាចេះជាងចេះអុយក៏គេចាត់ចែងអោយទៅអោយធ្វើផ្ទះគំរូអោយដូចៗគ្នា!

ក៖ ចាំយល់ហើយអ៊ុំ! ចុះហេតុអីបានសម្លាប់គាត់ដែរបើប្រើគាត់ហើយ?

ខ៖ គេថាយើងមិនទាន់ចេះទេគេចង់អោយយើងរៀនបំប៉ន! បំពេអោយគ្រប់អោយចេះអោយច្បាស់ជាងនេះដល់យកទៅថាអោយរៀនជំមិនអោយរៀនក៏ចងដាក់ឡានម៉ាឡានឪខ្ញុំចេញទៅលិចហើយ!

ក៖ ចាំចង់និយាយថានៅពេលដែលប្រើយើងធ្វើផ្ទះនិងហើយបានគេយកយើងទៅសម្លាប់ចោលអ្ហោះអ៊ុំ?

ខ៖ ធ្វើមិនទាន់រួចទេតែគេអោយទៅប្រជុំគេដើរប្រាប់តាមផ្ទះ!

ក៖ គេចង់សម្លាប់និងអ្ហាសអ៊ុំ!

ខ៖ គេដើរប្រាប់តាមផ្ទះអើណាំគេប្រាប់ថាអោយមិត្តទៅប្រជុំ!

ក៖ អ៎!

ខ៖ គេថាមិត្តទៅប្រជុំគេបើកធ្វើអង្គប៊ីទិញ!

ក៖ ចាំ!

ខ៖ តែឪខ្ញុំគាត់ដឹងហើយតែគាត់នៅតែចង់ទៅ!

ក៖ គាត់ដឹងថានិងអញ្ចឹងណោះអ៊ុំណោះ?

ខ៖ ចាំ។

ក៖ តែគាត់នៅតែសង្ស័យថាញ៉ឹងមែនឬក៏មិនមែនគាត់ទៅអោយអស់ចិត្តគាត់ចាំតែ!

ខ៖ បើទៅកុំយកអាខ្សែអន្រ្ទឹងអាអញ្ចេះៗទៅដាក់អាខ្សែលីឡុងយើងចងក្របីធម្មតាតែដាកលទៅគេចងគាត់ហើយគាត់ដាក់ខ្សែអន្រ្ទឹងទៅក៏គេចងគាត់តែគាត់ដឹងហើយយើងហាមឃាត់មិនអោយគាត់ទៅអោយគាត់រត់រំដោះមកស្រុកនេះទៀតែគាត់មិនម៉ោ។

កៈ ចា៎អញ្ចឹងគាត់ស្លាប់តាំងពីពេលនិងអញ្ចឹងកាលនិងអ៊ុំអាយុប៉ុន្មានបានអ៊ុំអាចចាំរឿងច្រើនអ៊ុំ?

ខៈ អូយមិនដឹងប៉ុន្មានតេស។

កៈ ដប់ឆ្នាំជាងអ្លេដឹងអ៊ុំ?

ខៈ ពេលនិងធំដែរ។

កៈ អ៊ុំអាចដឹងក្ដីហើយពេលនិងអ្ហោះ! អញ្ចឹងអ៊ុំអាចដឹងរឿងរ៉ាវ។

ខៈ ខ្ញុំកើតអើនៅកន្លែងកុមារមណ្ឌលកុមារគេយកទៅដាក់កុមារគេដាក់កុមារ! កុមារក៏ចល័តដែរគេអោយដាំដំឡូងកាប់ដីរើសនិងកាប់ស្មៅធ្វើទាំងអស់នៅតាមសហករ៍អូសអ៊ុំមិនបាននៅជាមួយម៉ែផង!

កៈ គេតម្រូវអោយចាកចេញពីម្ដាយអ្ហោះអ៊ុំអ្ហោះអត់អោយនជាមួយគ្នាទេ?

ខៈ អើគេអត់អោយនៅទេ! គេអោយរស់នៅផ្សេងៗគ្នា។

កៈ អញ្ចឹងអ៊ុំអត់សូវទទលបានភាពកក់ក្ដៅពីឪពុកម្ដាយទេ?

ខៈ ធ្វើមិចនិងបានបើម៉ែឪសុទ្ធតែនៅឆ្ងាយនិងម៉ែឪនៅផ្សេងកូននៅផ្សឹង!

កៈ ចា៎កាលនិងមិនមែនទាមទារភាពកក់ក្ដៅទេគឺទាមទារជីវិតរស់មែនទេអ៊ុំគេមិនសម្លាប់ចោលវាសំណាងធំហើយណោះអ៊ុំណោះ? អញ្ចឹងឪពុកអ៊ុំបានស្លាប់! ហើយម្ដាយរបស់អ៊ុំបានរួចម៉ោផុតពីគុកនិងម៉ោតែពេលម្ដាយអ៊ុំម៉ោគាត់មានប្រាប់អ៊ុំថាក្នុងគុកមិចៗទេអ៊ុំ?

ខៈគាត់ថាពិបាកដែរប៉ុន្តែបានមិត្តគេរំដោះដូចថាគេស្គាល់យើងគាត់ស្គាល់គ្នាទៅគេអាណិតទៅណា៎

កៈ ទៅគេជួយយើងអីណោះអ៊ុំណោះ?

ខៈ ចា៎!

កៈ គេលួចលាក់ការអោយយើងចេអ្ហាស!

ខ៖ លាក់ការទៅគេខ្សឹបខ្សៀវរំដោះម៉ោកុំអីគាត់ស្លាប់ដូចតែគ្នា!

ក៖ អូយអ៊ុំអើយអ៊ុំអត់ទាន់ទៅមើលនៅក្នុងគុកទួលស្លែងទេគេធ្វើទុក្ខវេទនាណាស់សំណាងហើយអ៊ុំស្រីគាត់ចេញម៉ោរួចនោះអញ្ចឹងបានថា!

ខ៖ យើងវាគ្រាន់តាចង់និយាយថាឃើញថាគាត់បានតែនៅខាងក្រៅគុកងងឹតមិនបានចូលទៅដល់ក្នុងផងងងឹតឆឹងបើថាដូថាយើងអញ្ចេះគ្មានទៅនៅទេគេអោយគាត់ដាំបាយទៅធ្វើម្ហូបទៅ!

ក៖ អញ្ចឹងគាត់អត់សូវវេទនាអីទេ?

ខ៖ គាត់បានកូនទៅមួយផង!

ក៖ កូនទីប៉ុន្មានទៅជាមួយគាត់?

ខ៖ កូនពៅទៅមួយ!

ក៖ អ៎បានកូនពៅទៅមួយ។

ខ៖ ទៅក៏បានរាសីកូននោះវាឡើងផងទៅគេស្រលាញ់កូននោះទៅគេអត់អោយម៉ែនោះនៅក្នុងគុកអេ្ហ!

ក៖ អឺទៅអញ្ចឹងទៅ។

ខ៖ ប្អូនពៅនោះសស្អូសស្អាតទៅគាត់ទូលទៅគេស្រណោះថាអូសស្រលាញ់កូនគេហើយអោយកូនគេនៅក្រៅផងទៅ! បានត្រូវ។

ក៖ អ៎គេស្រលាញ់បែបមិចគេស្រលាញ់បែបយកជាគូឬក៏មិចអ៊ុំ?

ខ៖ អត់ទេកូនងា កូនទូចញ៉េបនិង!

ក៖ អ៎អញ្ចឹង!

ខ៖ ជិះតែកដើរតែក្នុងដុបម៉ែនាំដើរទៅណោះទៅណោះទូលមួយគេដាក់គេលើក!

ក៖ ចាំព្រោះមុខគាត់មានប្រជាប្រិយ៍អ្នកណាគេក៏ស្រលាញ់អញ្ចឹងអ្ហាំ!

ខ៖ និងឯង!

ក៖ អញ្ចឹងដូចជាសព្វថ្ងៃនិងតើបងប្អូនរបស់អ៊ុំគាត់រស់នៅក្បែរៗនេះណោះអ៊ុំណោះ?

ខ៖ ជិតនេះដែរ!

ក៖ អញ្ចឹងតើពួកគាត់មានជីវភាពធូរធារហើយ! ?

ខ៖ និងឯងធម្មតា!

ក៖ គាត់អាចមាន

ខ៖ ម៉ាក្រជាងគេនេះបងដែរគត់ជើង!

ក៖ គាត់គត់ដោយសារអីគេដែរអ៊ុំ?

ខ៖ ចាំសត្រូវមីនណាស់!

ក៖ ហេតុអីបានទៅត្រូវមីនអញ្ចឹងតើអ៊ុំអាចប្រាប់?

ខ៖ ទៅកាប់អូសទៅក៏ម៉ោវិញដឹកគោអោយទឹកនោះក៏ត្រូវទៅ!

ក៖ ចាំទៅគាត់ដាច់ជើងត្រឹមណាដែរ?

ខ៖ ត្រឹមនេសអូន!

ក៖ ក្រោមជង្គងបន្តិចណោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ ចុះគាត់ដើរបានទេ?

ខ៖ បាន! គាត់ដាក់ជើងទៅធ្វើកន្លែងអង្គការ។

ក ដាក់ជើងសប្បនិមិតអញ្ចឹងគាត់ធ្វើការងារអីដែរសព្វថ្ងៃ?

ខ៖ មានធ្វើអុយទេមើលក្របីចិញ្ចឹមក្របី។

កៈ អ៎ចាំគ្នាអត់ស្រែធ្វើមិនកើតនិងគេធ្វើអុយមិនកើតគ្នាធ្វើទិញតែអង្ករស៊ី។

កៈ ចប់ពាលខ្លះមានបុណ្យទានអអញ្ចឹងតើអ៊ុំបានជួបជុំបងប្អូនហូបអីជុំគ្នាទេអ៊ុំ?

ខៈ មានអុយមាន!

កៈ ទោវត្តទៅវ៉ាជុំគ្នាអញ្ចឹងអីណាស់?

ខៈ ទៅៗជុំបងជុំប្អូន!

កៈ ចាំធ្វើមិចម្ដាយឪពុកយើងគាត់ទៅអស់ហើយ! អញ្ចឹងសល់តែបងប្អូនទេមែនទេអ៊ុំ?

ខៈ ចាំ!

កៈ អញ្ចឹងពេលខ្លះអ៊ុំមាននឹកម្ដាយរបស់អ៊ុំទេនឹកម្ដាយឪពុកអីដែរ្លាប់អីអញ្ចឹងអ្នាស?

ខៈ នឹកនិយាយមិននឹកយ៉ាងមិច!

កៈ នឹកណោះអ៊ុំណោះពិសេសពេលអ៊ុំនាគចិញ្ចឹមកូនតទៀតអ្នាសៅមានអារម្មណ៍ថាដូចធ្វើតាមម្ដាយព្រោះម្ដាយអ៊ុំធ្លាប់ធ្វើអញ្ចឹងដែរ!

ខៈ ពេលពេលបានជីវភាពគ្រប់គ្រាន់នឹកឃើញដល់ម៉ែឪ!

កៈ ចាំតែអត់អីដូចថាពេលបុណ្យទានអីអ៊ុំធ្វើតាមដែរថាប្រពៃណីរបស់អ៊ុំណោះអ៊ុំណោះ? ចាំ!

ខៈ គាត់មិនបានអង្កាលនៅមានគាត់យើងអត់ដល់ពេលយើងមានបាត់គ្មានបានថៃរក្សាម៉ែឪ។

កៈ ចាំគាត់ទៅអស់បាត់ទៅហើយ! ស្ដាយមែនទែន!

ខៈ តែយើមិនមែនមានហើយអត់ធ្វើអ្ហែមែនអ្ហែះអ៊ុំដោយសារតែយើងអត់ពេលយើងអត់អីណាំអ៊ុំអញ្ចឹងស្ថានកាលវាជំរុញអោយបែបនិង!

ខៈ ធ្វើក៏មិនបានដូចយើងនៅរស់!

កៈ ចាំល្អមែនទែនអ៊ុំយល់ចំណុចនិងអញ្ចឹងដូចជា! អញ្ចឹងតើម្ដាយរបស់អ៊ុំគាត់ឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះ បិទ!

ក៖ បិទ?

ខ៖ ចាំបិទ!

ក៖ អចាំត្រកូលគាត់ទេ!

ខ៖ ទេព!

ក៖ អញ្ចឹងគាត់ឈ្មោះទេព បិទ!

ខ៖ ចាំ!

ក៖ អំចាំចុះគាត់ស្លាប់នៅអាយុប៉ុន្មានដែរអ៊ុំដឹងទេ?

ខ៖ គាត់ស្លាប់និងអាយុគាត់ហុកសិបប្រមួយ!

ក៖ អំដោយសារជំងឺណោះអ៊ុំណោះ?

ខ៖ គាត់ឈឺពីរបីដងហើយតែមើលជាទៅក៏ជាទៅក៏ឈឺទៀត!

ក៖ ជំងឺនិងជាជម្ងឺអីដែរអ៊ុំ?

ខ៖ គាត់វង្វេង! គឺដូចថាគាត់ទៅសានៈធម៌ពីរបីដងទៅក៏មានអ្នករស់វិកជាមួយគាត់ទៅក៏វង្វេង គេហៅថាលប់ព្រះវីព្រះធម៌។

ក៖ អញ្ចឹងអ្ហោះ?

ខ៖ មើលមិនជា!

ក៖ មានអញ្ចឹងដែរអ្ហោះអ៊ុំ?

ខ៖ មានតាសតែយើងទៅសានៈហើយកូនចៅទៅរស់វិកទរស់វិកកន្លែងគាត់គឺដឹងតែយ៉ាប់គេ មិនអោយយើងទៅរញ៉េរញ៉ៃគាត់ទេ!

ក៖ ចាំអ៊ុំ! ឪពុករបស់អ៊ុំមានឈ្មោះអីដែរអ៊ុំ?

ខ៖ គី!

ក៖ អញ្ចឹងឪពុករបស់អ៊ុំឈ្មោះគី អ្ហោះ?

ខ៖ គី!

ក៖ គីចាំអញ្ចឹងគាត់ចែកឋានតាំងពីអាយុប៉ុន្មានអ៊ុំចាំទេ?

ខ៖ ឪពុកខ្ញុំតាំងពីជំនាន់អាពតនោះឯង!

ក៖ អំចំអញ្ចឹងគាត់មុននិងចូលអាពតគាត់មានមុខរបរអីដែរ? អ្នកធ្វើស្រែចំការអ្ហោះអ៊ុំណោះ?

ខ៖ ធ្វើជាងផ្ទះជាងអុយជាងមេការជាងខាង។

ក៖ តែម្ដាយរបស់អ៊ុំជាមេផ្ទះគាត់នៅផ្ទះ?

ខ៖ ចាំ!

ក៖ អំចាំចុះអ៊ុំមានចាំអំពីចរិតលក្ខណៈរបស់គាត់ទេថាគាត់ជាមនុស្សកាចឬក៏ស្លូតដែរអ៊ុំ?

ខ៖ ឪខ្ញុំស្លូតណាំមិនដែរវ៉ៃកូនទេគាត់ស្លូត!

ក៖ អូចុះម្ដាយអ៊ុំវិញមានចរិតបែបណាដែរ?

ខ៖ ម៉ែកាចដែរតែក៏មិនដែរវ៉ៃកូនដែរបើវ៉ៃវាទាល់តែយើងខុសណាស់អ្ហោះ?

ក៖ ចាំ!

ខ៖ បើល្មមៗគាត់មិនវ៉ៃទេ!

ក៖ ចាំចុះយាយតាខាងម្ដាយវិញតើអ៊ុំចាំទេ? ទាក់ទាងទៅនិងឪពុកម្ដាយរបស់ម្ដាយអ៊ុំទៀតអ៊ុំស្គាល់ឈ្មោះគាត់ទេ?

ខ៖ អូភ្លេចអស់ទៅហើយ!

ក៖ ភ្លេចឈ្មោះហើយណោះអ៊ុំណោះ។

ខ៖ តាទេព្យយាយទេព្យស្អីទេយាយណាយាយណាទេ។

ក៖ ភ្លេចឈ្មោះអស់ហើយអញ្ចឹងឈ្មោះយាយតាខាងឪពុកក៏អត់ចាំដែរអ្ហោះអ៊ុំយាយតាខាងឪពុកមានចាំទេមានឈ្មោះអីខ្លះទៅ?

ខ៖ ឈ្មោះអុយទេខាងឪអ្ហោះ។

ក៖ ភ្លេចបាតហើយអ៊ុំយរពេក!

ខ៖ ប្អូនខ្ញុំគេចាំតាស!

ក៖ តែអ៊ុំដូចថាមមារញ៉ីកខ្លាំងពេកទៅភ្លេចអីណោះអ៊ុំ។

ខ៖ អ៊ុំមិនចាំនិងគេទេថ្ងៃនោះគ្រាន់តែគេប្រាប់ថាអោយធ្វើចុងភៅទាល់តែតេម៉ោណំបានចាំ! ខំក៏អត់និងមិនដែរដឹងចាំទេ!

ក៖ អញ្ចឹងអ៊ុំអត់មានសាច់ញ្ញាតិណានៅក្រៅប្រទេសទេ?

ខ៖ អត់ទេ!

ក៖ ចាំចុះស្វាមីរបស់អ៊ុំឈ្មោះអីដែរអ៊ុំ?

ខ៖ នេះម៉ោហើយ!

ក៖ គាត់ឈ្មោះអីគេដែរ?

ខ៖ រីន!

ក៖ គាត់មានឈ្មោះថា រីន! តែគាត់អត់អីទេណោះអ៊ុំណោះគាត់ស្លូតឬកាចដែរ?

ខ៖ គួរសមដែរ!

ក៖ គួរសមណោះអ៊ុំណោះ?

ខ៖ និងហើយ!

ក៖ ជំរាបសួរ! គាត់មានមុខរបរអីគេដែរ?

ខ៖ ធ្វើស្រែនេះឯងនិងរកអីតិចតួច!

ក៖ អ៎ចាំហើយធ្វើស្រែបង្វះស្រែយកស្រូវគេអ្ហោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ អញ្ចឹងអ៊ុំអត់មានដីខ្លួនឯងទេ?

ខ៖ អត់ទេជូល!

ក៖ តែធ្វើស្រែអោយគេទៅគេអោយស្រូវមកវិញខ្លះ?

ខ៖ ចាំនោះឯង!ជួលគេ មួយហិចតាមួយរយដុល្លា?

ក៖ គេជួលអ៊ុំអ្ហោះ?

ខ៖ ចាំក្នុងមួយឆ្នាំ!

ក៖ ក្នុងមួយឆ្នាំធ្វើឬក្នុងមួយខែដែរ?

ខ៖ មួយឆ្នាំ!

ក៖ មួយឆ្នាំមួយរយដុល្លំលា?

ខ៖ យើងជួលគេណាស់មួយឆ្នាំមួយរយ!

យើងយកស្រូវម៉ោលក់បានរាប់ពាន់ប៉ុន្មានយ៉ាងតិចក៏មួយពាន់។

ក៖ អ៎ចាំអញ្ចឹងមានន័យថាអ៊ុំមានដីហើយ?

ខ៖ ចាំនិងហើយ!

ក៖ តែអ៊ុំជួលគេធ្វើ?

ខ៖ ទេក៏មានដីទេយើងជួលពីរគេម៉ោ!

ក៖ អ៊ុំជួលដីគេធ្វើ

ខ៖ និងឯង!

ក៖ អ៎យល់ហើយចាំទម្រាំតែយល់! (សើច)

ខ៖ យើងឯណាទៅមាននោះយើងជួលពីគេមកធ្វើយកតែស្រូវនិងណា!

ក៖ ចាំអញ្ចឹងអ៊ុំជួបស្វាមីរបស់អ៊ុំនៅស្រុកកំណើតនេះម្លោះអ៊ុំស្រុកទីនេះតែម្តងម្លោះ?

ខ៖ អត់ទេជួបនៅបាយ៉ាយគោកពោធិ៍!

ក៖ អ៊ុំទៅធ្វើអីនៅទីនោះដែរ?

ខ៖ ទេគេធ្វើទេហ៊ាននេះតើ!

ក៖ អ៊ូស្វាមីរបស់អ៊ុំគាត់ធ្វើទាហ៊ាន! អញ្ចឹងអ៊ុំទៅជួបាត់ពេលគាត់ធ្វើទាហ៊ានម្លោះ?

ខ៖ ទេ! ក៏បានទៅជួបគេសគេទៅឈរជើងទៅក៏ម៉ោវិញយើញក៏

ក៖ អីយ៉ាអ៊ុំនេះជានិស័យច្បាស់ក្រឡែតម៉ងម្លាសអ៊ុំ! នៅលើផែនដីយើងនេះមានមនុស្សច្រើនអីណាំអ៊ុំមិចក៏បានជួបអ៊ុំម៉ោរៀបអាពាហ៍ពិពាហ៍អីអញ្ចឹងទៅ! ចុះអ៊ុំស្រីអ៊ុំរៀនបានត្រឹមកម្រិតណាំដែរអ៊ុំ?

ខ៖ អ្ហឺថ្នាក់ទីពីភ្លេចអស់ទៅទៀតបាត់ទៅហើយ!

ក៖ ពេលនិងរៀនអំពីក ខ ណោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ អញ្ចឹងតើអ៊ុំអាចសរសេរឬក៏អានអក្សរខ្មែរបានទេ?

ខ៖ អូមិនបាច់និយាយទេសព្វថ្ងៃចប់!

ក៖ ភ្លេចហើយណោះអ៊ុំណោះ? ចាំ!

ខ៖ ខ្ញុំរៀនដូចក្មេកបន្ទោអញ្ចេះណោះ!

ក៖ ចុះកាលអ៊ុំរៀនអ៊ុំរៀនសាលាណាដែរអ៊ុំ?

ខ៖ រៀននៅសាលាច្រៀវអក្ខរកម្មផងអីផងញ្ញតែវាលខ្ញុំវាមិនចេះ។

ក៖ (សើច)ពេញតែវាលណោះអ៊ុំណោះ? អញ្ចឹងជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរហើយមែនទេអ៊ុំ? ដោយសារពីទូចដែរអ៊ុំរស់នៅជាមួយឪពុកម្តាយឆ្លងកាត់តាំងពីរឿងអាពតនោះផងវេទនាណាស់ណោះអ៊ុំណោះ?

ខ៖ ចាំមិនដែរបានរៀនទេ!

ក៖ តែឥលូវអ៊ុំធូរស្រោលជាងមុខណោះអ៊ុំណោះ?

ខ៖ ធូរ!

ក៖ អំចាំ! ចុះអ៊ុំមានកូនប៉ុន្មាននាក់ដែរ?

ខ៖ ប្រមួយ

ក៖ ប្រាំមួយនាក់! ស្រីប៉ុន្មានប្រុសប៉ុន្មានដែរអ៊ុំ?

ខ៖ ប្រុសពីរស្រីបួន!

ក៖ ប្រុសពីរស្រីបួន! តើអ៊ុំអាចរៀបរាប់ឈ្មោះរបស់ពួកគាត់តាំងពីកូនច្បងរហូតដល់កូនពៅបានទេ?

ខ៖ ឈ្មោះ រ័ត្ន!

ក៖ កូនច្បងឈ្មរ័ត្ន?

ខ៖ និងអ្អើយ!

ក៖ ចុះកូនបន្ទាប់ៗទៀត?

ខ៖ ឈ្មោះ ដា!

ក៖ អំឈ្មោះ ដាចាំ!

ខ៖ ទីបីឈ្មោះ លីស!

កៈ ចាំចុះទីបួន?

ខៈ ទីបួនឈ្មោះ គង្គារ!

កៈ គង្គារចាំ!

ខ ទីប្រាំឈ្មោះសារ៉ាត់!

កៈ អ៎ចាំអ៊ុំ!

គៈ ទីប្រាំមួយ ឈ្មោះសាគន្ធ!

ខៈ នោះឯងទីប្រាំមួយឈ្មោះ សាគន្ធ!

កៈ  ចាំ! អញ្ចឹងពួកគាត់សុទ្ធតែមានគ្រួសាររៀងៗខ្លួនឬក៏នៅពៅគេឬក៏! ?

ខៈ នៅពីរនៅលីវពីរផុតពីនោះគេបានអស់ហើយ!

កៈ អ៎អ្នកដែរនៅនិងគាត់មានមុខរបររៀងៗខ្លួនគាត់ឬក៏គាត់រៀនសូត្រដែរអ៊ុំ?

គៈ រៀនមួយអត់មួយ!

ខៈ រៀនមួយអត់មួយ!

កៈ ចាំអញ្ចឹងពួកគាត់សុទ្ធតែមានគ្រួសាររៀងៗខ្លួនហើយមុខរបររៀងៗខ្លួនទៀត!

ខ នោះឯង!

កៈ អញ្ចឹងអ្នកដែរនៅក្នុងបន្ទុកអ៊ុំសព្វថ្ងៃមានតែមួយទេណោះអ៊ុំណោះ?

ខៈ ពីរ!

កៈ នៅមានតែពីរនាក់ទេ! អត់មានគ្រួសារទាំងពីរនិង! តែអ៊ុំអាចនៅតែបន្តមានជីវភាពដើម្បីចិញ្ចឹមបីបាច់គាត់បានអត់អីទេ!

ខៈ ចាំ!

ក៖ ចុះមុខម្ហូបវិញតើអ៊ុំចូលចិត្តមុខម្ហូបអីដែរ? មុខម្ហូបដែរអ៊ុំចូលចិត្តម្ហាសឈ្មោះថាអីដែរ!

ខ៖ (សើច)!

គ៖ ម៉ាក់ឯងប្រាប់គាត់ទៅថាម៉ាក់ចូលចិត្តសម្លរកកូរ!

ខ៖ សម្លរប្រហើរ

សម្លរកកូរ(សើច)!

ក៖ ណ៎កបងគាត់ដឹងអ្នកគាត់ដឹងថាអ៊ុំចូលចិត្តសម្លរកកូរ

គ៖ ប្រហើរហើយនិងកកូរ!

ខ៖ ប្រហើរហើយនិងកកូរអញ្ចឹងឆាអីអត់សូវទេ!

គ៖ ឆាយូរៗម្តង!

ក៖ ចូលចិត្តទឹកៗជាង!

ខ៖ យើងអ្នកស្រែត្រូវចូលចិត្តសម្លរចូលចិត្តទឹកៗ!

ក៖ ចុះចម្រៀងអ៊ុំចូលចិត្តស្តាប់ទេ?

ខ៖ អូចេះមើលតទូរទស្សន៍

ក៖ ចូលចិត្តតែមើលទូរទស្សន៍ទេណោះអ៊ុំណោះ? ចុះអ៊ុំធ្លាប់ដូចថាចូលចិត្តច្រៀងខារ៉ាអូខេអីធ្លាប់ទេ?

គ៖ គាត់អត់ចេះច្រៀងទេចេះតែស្តាប់!

ក៖ អ៎ចេះតែស្តាប់អ្ហេសណោះអ៊ុំណោះ?

ខ៖ ចេះតែស្តាប់ទេខ្ញុំ!

ក៖ អ៊ីចាំសម្លេងរបស់អ៊ុំបើច្រៀងមួយបទមិនដឹងពីរោះយ៉ាងណាទេ

ខ៖ ពិរោះខ្មោចយំអីខ្ញុំគ្រុនផ្ដាស់សាយសម្លេងឡើងងុលៗ!

ក៖ ចាំចុះដូចជាក្នុងគ្រួសាររបស់អ៊ុំមានអ្នកណាចេះលេងឧបករណ៍ភ្លេងខ្មែរទេអ៊ុំ?

ខ៖ អត់!

ក៖ អត់មានអ្នកណាចេះខាងសិល្បៈទេណោះអ៊ុំ?

ខ៖ ចេះមីពៅគេនោះវាទៅរបាំ

ក៖ អូគាត់ចេះរាំរបាំ!

គ៖ បានកូនច្បងមួយដែរតែឈប់ហើយ!

ក៖ កូនច្បងនោះធ្លាប់ធ្វើអីគេដែរបង?

ខ៖ រាំ!

គ៖ រាំរបាំ!

ក៖ អ់រាំរបាំរហូតតមកកូនពៅមួយទៀតរាំរបាំដែរ!

ខ៖ គេចំណូលខាងណាក៏ទៅៗ!

ក៖ ចាំ! មានអ្នកណាចិត្តបានដូចម្ដាយនេះទៀតទេចុះដូចជាតើអ៊ុំស្រីមានជំនាញដែរតពីឪពុកម្ដាយម៉ោអ្នាស?

ខ៖ មិនដឹងជំនាញអី!

ក៖ ដូចថាអ៊ុំធ្លាប់ធ្វើ កន្ទេល ផ្ដៅ ធ្វើអន្រ្ទឹងអីអញ្ជឹងអ្នាស? ង

ខ៖ ក៏ដែរចេះទេទិញតែគេ!

ក៖ ទិញតែគេទេណោះអ៊ុំណោះ? (សើច)ចេះទិញគេមែនទេអ៊ុំ?

ខ៖ ចេះតែទិញគេអត់ចេះត្បាញចេះអីទេ!

កៈ ចាំអញ្ចឹងក្រៅពីមុខរបរធ្វើស្រែចំការអ៊ុំមានធ្លាប់ដើរលក់ដូរអីដែរថាមានទុក្ខលំបាកអីទៀតទេ?

ខៈ អត់ទេធ្លាប់ចេះតែដាំបន្លែខ្លួនឯងលក់ប៊ុនណោះឯង!

កៈ អ់ចាំដូចថាអ៊ុំធ្លាប់លក់បន្លែលក់អីញ្ចឹងទៅ!

ខៈ ចេះដាំតែបន្លែ!

កៈ អញ្ចឹងតើអ៊ុំស្រីដូចថាអាចមានពាក្យពេចន៍អីផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយដែរទេដូចថា

ខៈ មិនដឹងជានិយាយអី!

កៈ (សើច)អូចាំអ៊ុំអៀនអ្ហាស!ពួកគាត់ដែរកំពុងតែរៀនសូត្រអញ្ចឹងអ្ហាសពួកគាត់ត្រូវការនិងចង់បានពាក្យទូន្មានពីអ៊ុំស្រីអញ្ចឹងទៅ!

កៈ ចាំញ្ចឹងតើអ៊ុំអាចចែកចាយបានទេ?

ខៈ មានអុយ(សើច)! វាយ៉ាប់មិនសូវចេះនិយាយ!

កៈ ចាំអ៊ុំអាចចែកចាយទាក់ទងនិងការសិក្សារបស់ពួកគាត់អញ្ចឹងអឺណាំអ៊ុំ?

ខៈ អោយតែកនខំរៀនសូត្រនោះ

ឯង!

កៈ ពេលដែរគាត់ខំរៀនសូត្រ

ខៈ ម៉ែនេះល្ងង់ហើយកុំល្ងង់ដូចម៉ែ!

កៈ អ់ចាំអញ្ចឹងសព្វថ្ងៃនិងអ៊ុំស្រីនៅតែលើកទឹកចិត្តអោយពួកគាត់ទៅរៀនអ្ហាសមែនទេអ៊ុំ?

ខៈ អោយទៅរៀននោះឯង!

កៈ ព្រោះអ៊ុំដឹងថាការសិក្សាវាសំខាន់

ខៈ ចាំអោយតែចេះទៅយើងមានការងារធ្វើ

កៈ ចា!

ខៈ ម៉ែនេះបានចុកអ្ហើយ!

កៈ (សើច)អរគុណច្រើនអ៊ុំក្នុងឱកាសដែរអ៊ុំបានផ្តល់ពេលវេលាមួយដែរក្មួយអាចសំភាសន៍អ៊ុំទាក់ទងទៅនិងជីវប្រវត្តិរបស់អ៊ុំផងដែរហើយពួកយើងសុំការអនុញ្ញាតពីអ៊ុំដើម្បីដាក់សម្លេងរបស់អ៊ុំនិងចូលទៅក្នុងគេហទំព័ររបស់ពួកយើងដើម្បីអោយកូនចជំនាន់ក្រោយគេបានស្តាប់លឺណោះអ៊ុំណោះ?

ខៈ ចាំ!

កៈ ក៏ដូចជារូបថតរបស់អ៊ុំផងដែរដើម្បីអោយក្មេងជំនាន់ក្រោយគេបានស្គាល់និងបានយល់អំពីខ្សែជីវិតរបស់អ៊ុំអីណាស់អ៊ុំ? អញ្ចឹងតើអ៊ុំយល់ព្រមដើម្បីយើងអាចដាក់ចូលបានទេ?

ខៈ (សើច)!

កៈ បានទេអ៊ុំ?

ខៈ ចាំបាន!

កៈ អូអរគុណច្រើនហើយពួកយើមានតែប៉ុននិងសូមជំរាបលាអ៊ុំស្រី!

ខៈ ចាំសុខសប្បាយ!